DOCUMENTATION OF GENERAL DIRECTORATE OF AGRICULTURE

# ប្រកាស ០៩៩ ប្រក.កសក

(១០/០៣/២០១០)

# ស្តីពី

# ការដាក់ឱ្យប្រើប្រាស់

# វិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារ

# ផលិតកម្មផ្លែឈើ និងបន្លែស្រស់



# Proclamation
# No.099 MAFF, 10/03/2010
# on the Issuing of Good Agricultural Practice in Production of Fresh Fruit and Vegetable

Note: This MAFF Ministerial Proclamation is in Khmer Language, with consisted by 4 Chapters as annex: Food Safety, Product Quality, Worker Health and Welfare and Environment Management.

(ALL REQUIREMENTS IN THIS TECHNICAL REGULATION ARE BASE ON ASEANGAP)

No.54B/ 49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh, Cambodia/ Fax:(855)23 883 267/ E-Mail: hearvanhan@gmail.com

Created with nitroPDF professional
download the free trial online at nitropdf.com/professional

**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
Ministry of Agriculture Forestry and Fisheries

លេខ ០៩៩ ប្រក.កសក

អគ្គនាយកដ្ឋានកសិកម្ម
ចូល 1340
ថ្ងៃ 24-05-10 ម៉ោង 10:00
បញ្ជូន

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់វិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី.១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/
Phone : (023) 726 128 / 726 129

Created with nitroPDF professional
download the free trial online at nitropdf.com/professional

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារ ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ និងកែលំអរដឹកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ សេចក្តីសម្រេចរបស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន លើកទី ២៨ នាថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នៅប្រទេសសឹង្ហបុរី
- បានឃើញ ប្រកាសលេខ ៣៣៤ ប្រក.កសក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ ១:** ប្រកាសនេះ សំដៅដាក់ឱ្យប្រើប្រាស់នូវវិធាននៃការអនុវត្តកសិកម្មល្អ (Good Agricultural Practices – GAP) ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ដើម្បីលើកកម្ពស់សុវត្ថិភាពចំណីអាហារ ទប់ស្កាត់ការប៉ះពាល់បរិស្ថាន ការពារសុខភាព សុវត្ថិភាព និងសុខុមាលភាពអ្នកផលិត ព្រមទាំងលើកកម្ពស់គុណភាពកសិផល និងធ្វើឱ្យប្រសើរឡើងដល់សុខដុមនីយកម្មនៃស្តង់ដារផលិតផល និងសម្របសម្រួលពាណិជ្ជកម្មផ្លែឈើ និងបន្លែស្រស់នៅលើទីផ្សារ ។

**ប្រការ ២:** វិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ មិនរាប់បញ្ចូលនូវផលិតកម្មនៃផលិតផលកសិកម្មដទៃទៀតឡើយ ។

**ប្រការ ៣:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើការដាំដុះ ឬ ធ្វើពាណិជ្ជកម្ម ផ្លែឈើ និងបន្លែស្រស់ ត្រូវបានទទួលការអប់រំ និងជំរុញឱ្យអនុវត្ត និងគោរពតាមវិធាននៃការអនុវត្តកសិកម្មល្អ ដើម្បីធានាបានថា ផលិតផលទាំងនោះ មានគុណភាពល្អ និងមានសុវត្ថិភាពក្នុងការបរិភោគ ។

វិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

Created with nitro PDF professional
download the free trial online at nitropdf.com/professional

ប្រការ ៤: អគ្គនាយកដ្ឋានកសិកម្មត្រូវទទួលខុសត្រូវរៀបចំអនុវត្តប្រព័ន្ធយន្តការគ្រប់គ្រងការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ និងជាអង្គភាពគ្រប់គ្រង និងចេញវិញ្ញាបនបត្រអនុលោមភាពតាមវិធាននៃ

ប្រការ ៤: អគ្គនាយកដ្ឋានកសិកម្មត្រូវទទួលខុសត្រូវរៀបចំអនុវត្តប្រព័ន្ធយន្តការគ្រប់គ្រងការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ និងជាអង្គភាពគ្រប់គ្រង និងចេញវិញ្ញាបនបត្រអនុលោមភាពតាមវិធាននៃការអនុវត្តផលិតកម្មល្អ (Certificate of GAP Compliance) ។

ប្រការ ៥: ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦: អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

Created with nitroPDF professional
download the free trial online at nitropdf.com/professional

ឧបសម្ព័ន្ធនៃប្រកាសលេខ ៩៩ ប្រក.កសក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១០

## ស្តីពីការដាក់ឱ្យប្រើប្រាស់វិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់

# I. FOOD SAFETY

# ១. ផ្នែកសុវត្ថិភាពចំណីអាហារ

## ក. ប្រវត្តិទីកន្លែងផលិតកម្ម និងការគ្រប់គ្រង

១ ត្រូវធ្វើការវាយតម្លៃហានិភ័យដែលអាចបង្កធ្វើឱ្យកខ្វក់ដល់កសិផល ដោយសារធាតុគីមី និងជីវសាស្ត្របង្កគ្រោះថ្នាក់ ដែលបន្សល់ពីការប្រើប្រាស់ពីមុន ក្នុងកន្លែង ឬក៏នៅជាប់កន្លែងដែលនឹងត្រូវធ្វើផលិតកម្មរាល់មុខដំណាំ ដោយកត់ត្រា និងរក្សាកំណត់ត្រានូវរាល់ហានិភ័យដែលបានធ្វើអត្តសញ្ញាណ។

២ មិនត្រូវប្រើទីកន្លែងណាដែលលទ្ធផលនៃការវាយតម្លៃបង្ហាញថា អាចនឹងមានហានិភ័យខ្ពស់ ក្នុងការបង្កភាពកខ្វក់ ដោយសារធាតុគីមី និងជីវសាស្ត្រដល់ផលិតផលឡើយ ឬត្រូវចាត់វិធានការទប់ស្កាត់ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះជាមុន ក្នុងករណីដែលអាចធ្វើបាន។

៣ ត្រូវធ្វើការត្រួតពិនិត្យ តាមដានលើវិធានការគ្រប់គ្រងហានិភ័យ ដើម្បីឱ្យប្រាកដថា ពិតជាមិនមានបង្កភាពកខ្វក់ទៅលើផលដំណាំ និងត្រូវរក្សាទុកកំណត់ត្រាវិធានការនានាដែលបានប្រើ និងលទ្ធផលត្រួតពិនិត្យ។

៤ ត្រូវធ្វើកំណត់ត្រាទុក ចំពោះបណ្តាទីតាំងផលិតកម្មណាដែលមានភាពកខ្វក់មិនសមស្របសម្រាប់ផលិតកម្ម។

## ខ. ពូជ និងបំណែកពូជដំណាំ

៥ ត្រូវកត់ត្រាទុកអំពីការប្រើប្រាស់ប្រព្រឹត្តកម្មគីមី (ដូចជាការជ្រលក់ ឬ ត្រាំដោយថ្នាំជាដើម) ណាមួយ និងមូលហេតុនៃការប្រើប្រាស់ប្រព្រឹត្តកម្មនោះ ប្រសិន ពូជ ឬបំណែកពូជដំណាំ ត្រូវបានផលិតនៅក្នុងកសិដ្ឋាននោះ។

៦ ត្រូវកត់ត្រាទុកនូវឈ្មោះរបស់អ្នកផ្គត់ផ្គង់ និងកាលបរិច្ឆេទនៃការផ្គត់ផ្គង់ពូជ ឬ បំណែកពូជដំណាំ ដែលត្រូវបានផលិតពីទីកន្លែងផលិតកម្ម ឬកន្លែងបណ្តុះផ្សេង។

៧ មិនត្រូវដាំពូជដែលគេស្គាល់ថា ធ្វើឱ្យពុលដល់ការប្រើប្រាស់របស់មនុស្សឡើយ។

## គ. ជី និងសារធាតុកែលម្អបង្កើនជីជាតិដី

៨ ត្រូវធ្វើការវាយតម្លៃ និងកត់ត្រានូវរាល់ហានិភ័យដែលបង្កដោយការប្រើប្រាស់ ជី ឬ សារធាតុកែលម្អបង្កើនជីជាតិដី សម្រាប់ដំណាំនីមួយៗ។

៩ ត្រូវចាត់វិធានការដើម្បីកាត់បន្ថយហានិភ័យ ដែលបណ្តាលមកពីការប្រើប្រាស់ជី ឬ សារធាតុកែលម្អបង្កើនជីជាតិដី។ ត្រូវជ្រើសរើសជី ឬ សារធាតុកែលម្អបង្កើនជីជាតិដីណាដែលបង្កគ្រោះថ្នាក់ដោយបន្សល់សារធាតុលោហៈធ្ងន់តិចបំផុតនៅក្នុងផលិតផល។

Created with nitroPDF professional
download the free trial online at nitropdf.com/professional

១០ មិនត្រូវប្រើសារធាតុសរីរាង្គ (សំណល់ពីរុក្ខជាតិ មនុស្ស សត្វ អតិសុខុមប្រាណ ។ល។) ដែលពុំបានធ្វើប្រព្រឹត្តកម្ម (ចលនការរម្ងាប់មេរោគ-តាមវិធីរូបសាស្ត្រ គីមី ឬ ជីវសាស្ត្រ) ប្រសិនបើវាស្ថិតក្នុងស្ថានភាពដែលមានហានិភ័យខ្ពស់ ដែលអាចធ្វើឱ្យកខ្វក់ដល់កសិផល ។

១១ ត្រូវតែកត់ត្រាទុកនូវវិធីសាស្ត្រ កាលបរិច្ឆេទ និងរយៈពេលនៃការធ្វើប្រព្រឹត្តកម្ម ក្នុងករណីដែលបានធ្វើប្រព្រឹត្តកម្មសារធាតុសរីរាង្គនៅក្នុងទីកន្លែងផលិតកម្មមុននឹងប្រើ ។

១២ ត្រូវតែមានឯកសារពីអ្នកផ្គត់ផ្គង់ផលិតផលដែលមានផ្សំដោយសារធាតុសរីរាង្គ ក្នុងករណីដែលផលិតផលទាំងនោះទទួលបានពីប្រភពខាងក្រៅ ដើម្បីបង្ហាញថា សារធាតុសរីរាង្គទាំងនោះ ពិតជាបានធ្វើប្រព្រឹត្តកម្មកាត់បន្ថយហានិភ័យ ។

១៣ មិនត្រូវប្រើកាកសំណល់របស់មនុស្ស (លាមក ទឹកមូត្រ សំណល់ពីបង្គន់ ។ល។) នៅក្នុងផលិតកម្មកសិផលស្រស់ដែលមានគោលដៅសំរាប់ការប្រើប្រាស់ជាអាហារផ្ទាល់របស់មនុស្សឡើយ ។

១៤ ត្រូវពិនិត្យថែរទាំឧបករណ៍ដែលប្រើសម្រាប់ការដាក់ជី ឬ សារធាតុកែលម្អបង្កើនជីជាតិដី ឱ្យស្ថិតក្នុងស្ថានភាពដំណើរការល្អ យ៉ាងតិចមួយឆ្នាំម្តង ដោយអ្នកមានសមត្ថភាពបច្ចេកទេស ។

១៥ ត្រូវតែកំណត់ទីតាំងសាងសង់ ថែរក្សា កន្លែងលាយ កន្លែងផ្ទុកជី និងសារធាតុបន្ថែមទៅក្នុងដី និងសម្រាប់ធ្វើកំប៉ុស្តសារធាតុសរីរាង្គ ដើម្បីកាត់បន្ថយហានិភ័យនៃភាពកខ្វក់ដល់កន្លែងផលិតកម្ម និងប្រភពទឹក ។

១៦ ត្រូវកត់ត្រាទុកដោយលម្អិតអំពីប្រភព ឈ្មោះផលិតផល កាលបរិច្ឆេទ និងបរិមាណនៃជី ឬ សារធាតុកែលម្អបង្កើនជីជាតិដី ដែលទទួលយកមកទុកប្រើប្រាស់ ។

១៧ ត្រូវកត់ត្រាទុកដោយលំអិតអំពីកាលបរិច្ឆេទ ឈ្មោះផលិតផល ឬសម្ភារៈដែលបានប្រើ ទីតាំងធ្វើប្រព្រឹត្តកម្ម អត្រាប្រើប្រាស់ វិធីសាស្ត្រប្រើប្រាស់ និងឈ្មោះអ្នកប្រើប្រាស់ នូវរាល់ការប្រើជី ឬ សារធាតុកែលម្អបង្កើនជីជាតិដី ។

## ឃ.ទឹក

១៨ ត្រូវធ្វើការវាយតម្លៃទឹកដែលប្រើក្នុងដំណាក់កាលមុនពេលប្រមូលផល (ទឹកសម្រាប់ស្រោចស្រព សម្រាប់ដាក់ជី និងសម្រាប់លាយនឹងសារធាតុគីមីផ្សេងៗ) និងក្នុងដំណាក់កាលក្រោយប្រមូលផល (ទឹកសម្រាប់លាងសំអាតសម្រាប់ប្រព្រឹត្តកម្មកសិផល និងធ្វើអនាម័យ) ដើម្បីស្រាវជ្រាវរកហានិភ័យដែលអាចបង្កឱ្យមានភាពកខ្វក់ដោយសារធាតុគីមី និង ជីវសាស្ត្រដល់កសិផល ។

១៩ ត្រូវធ្វើការពិសោធន៍វាយតម្លៃទឹក ដើម្បីកំណត់ហានិភ័យបង្កឱ្យមានភាពកខ្វក់លើកសិផល ទៅតាមពេលវេលាដែលសមស្របនឹងលក្ខខណ្ឌដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់ទឹក និងត្រូវរក្សាកំណត់ត្រាលទ្ធផល ។

២០ ត្រូវតែជ្រើសរើសប្រភពទឹកដែលមានសុវត្ថិភាព ឬ ត្រូវធ្វើប្រព្រឹត្តកម្មទឹក និងត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ដោយមានកំណត់ត្រា និងរក្សាទុកកំណត់ត្រានៃវិធីសាស្ត្រធ្វើប្រព្រឹត្តកម្ម និងលទ្ធផលត្រួតពិនិត្យ សម្រាប់តំបន់ណាដែលហានិភ័យខ្ពស់នៃភាពកខ្វក់ដោយសារធាតុគីមី និងជីវសាស្ត្រ ។

២១ មិនត្រូវប្រើទឹកសំណល់ (ទឹកសម្អុយ) ដែលមិនបានធ្វើប្រព្រឹត្តកម្មនៅក្នុងពេលផលិតកម្ម ក្នុងការលើកដាក់ និងក្រោយពេលប្រមូលផលឡើយ ។ ការប្រើទឹកសំអុយដែលបានធ្វើប្រព្រឹត្តកម្មនោះ គុណភាពទឹកត្រូវតែអនុលោមទៅនឹងបទដ្ឋានដែលបានកំណត់ ។

Created with nitroPDF professional
download the free trial online at nitropdf.com/professional

## ១. សារធាតុគីមី

### ង.១. គ្រឿងគីមី:

២២ ត្រូវធ្វើការបណ្តុះបណ្តាលនូវចំណេះដឹងដែលទាក់ទងនឹងការប្រើប្រាស់សារធាតុគីមីដល់និយោជក និងកម្មករនៅក្នុងកសិដ្ឋានឱ្យសមរម្យទៅនឹងការងារទទួលខុសត្រូវរបស់ពួកគេ ។

២៣ ត្រូវមានភស្តុតាងអំពីសមត្ថភាពបច្ចេកទេស ប្រសិនបើការជ្រើសរើសសារធាតុគីមីមកប្រើប្រាស់ក្នុងផលិតកម្មត្រូវបានសម្រេចដោយទីប្រឹក្សា ឬសមត្ថកិច្ចជំនាញ។

២៤ ត្រូវប្រើប្រព័ន្ធវិធានការចម្រុះគ្រប់គ្រងសមាសភាពចង្រៃតាមការដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមីអសរីរាង្គ។

២៥ ត្រូវទិញសារធាតុគីមីពីអ្នកផ្គត់ផ្គង់ ដែលអាជ្ញាប័ណ្ណត្រឹមត្រូវ។

២៦ ត្រូវប្រើប្រាស់តែសារធាតុគីមី និងថ្នាំកសិកម្មជីវសាស្ត្រ ដែលអនុញ្ញាតឱ្យប្រើប្រាស់លើមុខដំណាំ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលមានបំណងនាំយកផលិតផលទៅលក់ ដោយត្រូវតែមានឯកសារតម្កល់គ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីការសម្រេចនោះ ។

២៧ ត្រូវចាត់ចែងវិធានការដាំដុះដើម្បីរក្សាកំរិតសំណល់ជាតិពុលក្នុងផលដំណាំ ឱ្យស្ថិតនៅទាបជាងកំរិតសំណល់ជាតិពុលដែលអាចកាត់ចោលបាន (MRLs) នៃសារធាតុគីមីដែលអនុម័តដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលនឹងលក់ ឬនាំយកផលិតផលទៅលក់ (ចំពោះការលក់នៅក្នុងប្រទេសកម្ពុជាត្រូវគោរពតាមការកំណត់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ។

២៨ ត្រូវធ្វើការវិភាគសំណល់ជាតិពុលក្នុងកសិផល ដើម្បីពិនិត្យតាមដានភាពត្រឹមត្រូវនៃការប្រើប្រាស់សារធាតុគីមី ជាប្រចាំទៅតាមពេលវេលាដែលតម្រូវដោយអតិថិជន ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលនឹងលក់ ឬនាំយកផលិតផលទៅលក់ (ចំពោះការលក់នៅក្នុងប្រទេសកម្ពុជាត្រូវគោរពតាមការកំណត់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ។ មន្ទីរពិសោធន៍ ដែលត្រូវវិភាគសំណល់ជាតិពុលក្នុងកសិផល សំដៅដល់មន្ទីរពិសោធន៍ជាតិកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរពិសោធន៍ផ្សេងៗទៀត ដែលមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

២៩ ត្រូវចៀសវាងការលាយបញ្ចូលគ្នានូវសារធាតុគីមីលើសពីពីរមុខ លុះត្រាតែបានទទួលអនុសាសន៍ពីអាជ្ញាធរមានសមត្ថកិច្ច (អគ្គនាយកដ្ឋានកសិកម្ម) ។។

៣០ ត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវក្នុងរយៈពេលរង់ចាំ រវាងការប្រើប្រាស់សារធាតុគីមី និងការប្រមូលផល ដោយអនុលោមតាមអនុសាសន៍នៃប្រភេទថ្នាំកសិកម្ម និងប្រភេទដំណាំ ដោយមានកំណត់ត្រា និងរក្សាកំណត់ត្រាឱ្យបានច្បាស់លាស់ ។

៣១ ត្រូវថែទាំឧបករណ៍ប្រើប្រាស់ជាមួយថ្នាំកសិកម្មឱ្យបានល្អ និងពិនិត្យមើលប្រសិទ្ធភាពការងារ យ៉ាងតិចណាស់មួយឆ្នាំម្តង ដោយភ្នាក់ងារមានសមត្ថភាពបច្ចេកទេស ។

៣២ ត្រូវលាងសំអាតឧបករណ៍ប្រើប្រាស់ជាមួយថ្នាំកសិកម្ម បន្ទាប់ពីរាល់លើកនៃការប្រើប្រាស់ ហើយសំណល់ពីការលាងទាំងនោះ ត្រូវចោលតាមរបៀបសមស្រប ដែលមិនបង្កនូវហានិភ័យធ្វើឱ្យកខ្វក់ដល់កសិផល និងបរិស្ថាន។

៣៣ ត្រូវចោលល្បាយថ្នាំកសិកម្មដែលលាយលើស តាមរបៀបសមស្របដែលមិនបង្កនូវហានិភ័យធ្វើឱ្យកខ្វក់ដល់ផលដំណាំ និងបរិស្ថាន។

Created with nitroPDF professional
download the free trial online at nitropdf.com/professional

៣៤ ត្រូវរក្សាទុកសារធាតុគីមីនៅកន្លែងដែលមានខ្យល់ចេញ-ចូលល្អ ក្នុងសំណង់រឹងមាំ និងមានសុវត្ថិភាព ដោយដាក់កំហិតឱ្យតែអ្នកដែលមានការអនុញ្ញាតចេញ-ចូលតែប៉ុណ្ណោះ។ ត្រូវកំណត់ទីតាំង និងការសាងសង់ឱ្យបានសមស្រប ដើម្បីកាត់បន្ថយហានិភ័យនៃភាពធ្វើឱ្យក្រខ្វក់ដល់កសិផល និងត្រូវបំពាក់ដោយសម្ភារៈសំរាប់សង្គ្រោះបន្ទាន់ ក្នុងករណីដែលមានការកំពប់សារធាតុគីមី។

៣៥ មិនត្រូវរក្សាទុកសារធាតុគីមីក្នុងទម្រង់រាវនៅពីលើធ្នើរដែលស្ថិតនៅខាងលើសារធាតុគីមីទម្រង់ម្សៅឡើយ។

៣៦ ត្រូវតែរក្សាសារធាតុគីមីនៅក្នុងកញ្ចប់/ធុង/ដបដើមរបស់វា ដែលមានស្លាកសញ្ញាស្របច្បាប់ និងត្រូវអនុវត្តទៅតាមការណែនាំដែលបញ្ជាក់លើស្លាកសញ្ញា ឬពីអាជ្ញាធរមានសមត្ថកិច្ច។ ប្រសិនបើមានការផ្ទេរសារធាតុគីមីទៅកាន់ធុង/ដបផ្សេងមួយទៀត ធុង/ដបថ្មីនោះ ត្រូវតែសរសេរចំណាំឱ្យច្បាស់ ដោយមានដាក់ឈ្មោះយីហោ កម្រិតប្រើប្រាស់ និងរយៈពេលរង់ចាំ។

៣៧ មិនត្រូវប្រើធុង/ដបថ្នាំកសិកម្មឡើងវិញឡើយ និងត្រូវរក្សាវាឱ្យមានសុវត្ថិភាពរហូតដល់ពេលកម្ទេចចោលតាមវិធីសមស្រប។

៣៨ ត្រូវកម្ទេចចោលធុង/ដបថ្នាំកសិកម្មដែលប្រើរួច តាមគោលការណ៍កំណត់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ ដើម្បីកាត់បន្ថយហានិភ័យនៃការធ្វើឱ្យក្រខ្វក់ដល់កសិផល និងបរិស្ថាន។

៣៩ ត្រូវតែធ្វើអត្តសញ្ញាណឱ្យបានច្បាស់លាស់ និងរក្សាទុកឱ្យបានត្រឹមត្រូវ រហូតដល់ពេលកម្ទេចចោលនូវសារធាតុគីមីដែលផុតកំណត់ប្រើប្រាស់ ដែលមិនអាចប្រើតទៅទៀតបាន ឬដែលមិនអនុញ្ញាតឱ្យប្រើតទៅទៀត ។

៤០ ត្រូវកម្ទេចចោលសារធាតុគីមីដែលផុតកំណត់ប្រើប្រាស់ តាមរយៈប្រព័ន្ធប្រមូលផ្ដុំជាផ្លូវការ ឬនៅតាមតំបន់ និងវិធីសាស្ត្រដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

៤១ ត្រូវតែកត់ត្រាទុក អំពីការប្រើប្រាស់សារធាតុគីមីលើដំណាំមួយមុខៗ ដោយបញ្ជាក់យ៉ាងពិស្តារអំពីសារធាតុគីមីដែលបានប្រើ មូលហេតុប្រើ កាលបរិច្ឆេទ និងទីតាំងដែលបានប្រើ កម្រិតប្រើប្រាស់ វិធីសាស្ត្រប្រើប្រាស់ រយៈពេលរង់ចាំ និងឈ្មោះអ្នកប្រើប្រាស់ ។

៤២ ត្រូវរក្សាទុកនូវឯកសារកត់ត្រាអំពីសារធាតុគីមីដែលយកមកទុកប្រើប្រាស់ ដោយមានបញ្ជាក់ពិស្តារអំពីឈ្មោះសារធាតុគីមី អ្នកផ្គត់ផ្គង់សារធាតុគីមី កាលបរិច្ឆេទ និង បរិមាណដែលបានបញ្ចូលស្តុក និងកាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ ឬកាលបរិច្ឆេទផលិត ។

៤៣ ត្រូវរក្សាទុកកំណត់ត្រាសារធាតុគីមីក្នុងស្តុក ដោយបញ្ជាក់លំអិតអំពីឈ្មោះគីមី កាលបរិច្ឆេទ និងបរិមាណទទួលចូល និងកាលបរិច្ឆេទនៅពេលដែលប្រើអស់ ឬនៅពេលដែលកម្ទេចចោល។

៤៤ ត្រូវតែបញ្ឈប់ការលក់ចែកចាយកសិផល ប្រសិនបើរកឃើញថា មានសំណល់សារធាតុគីមីលើសពីកំរិត MRLs។ ត្រូវធ្វើការស៊ើបអង្កេតអំពីមូលហេតុនៃភាពក្រខ្វក់នោះ និងចាត់វិធានការទប់ស្កាត់ដើម្បីចៀសវាងកើតមានឡើងជាថ្មី និងត្រូវកត់ត្រាទុកនូវហេតុការណ៍ដែលបានកើតឡើង និងវិធានការដែលបានប្រើ។

## ៦.២.សារធាតុគីមីដទៃទៀត

៤៥ ត្រូវប្រើប្រាស់ រក្សាទុក និងកម្ទេចចោល នូវប្រេងឥន្ធនៈ ប្រេង និងសារធាតុដែលមិនមែនជាក្សេត្រគីមីផ្សេងទៀត តាមរបៀបដែលអាចកាត់បន្ថយហានិភ័យបង្កឱ្យក្រខ្វក់ដល់កសិផល។

Created with nitro PDF professional
download the free trial online at nitropdf.com/professional

## ច. ការប្រមូលផល និងដំណើរការថែរក្សា ទុកដាក់កសិផល

### ច.១. ឧបករណ៍, ធុង/ប្រអប់ និងសម្ភារៈ

៤៦ ត្រូវតែប្រើឧបករណ៍ ប្រអប់/ធុង សម្រាប់ដាក់ ឬផ្ទុកកសិផលដែលធ្វើអំពីសម្ភារៈដែលនឹងមិនធ្វើឱ្យកខ្វក់ដល់កសិផល ។

៤៧ ត្រូវធ្វើអត្តសញ្ញាណ ប្រអប់/ធុង ដែលប្រើសម្រាប់ដាក់ ឬរក្សាទុកសំណល់សារធាតុគីមី និងសារធាតុបង្កគ្រោះថ្នាក់ផ្សេងទៀត ឱ្យបានច្បាស់លាស់ដើម្បីចៀសវាងការប្រើវាក្នុងការដាក់កសិផល ។

៤៨ ត្រូវតែថែរទាំ សំអាតសម្ភារៈ ឧបករណ៍ និងធុងឱ្យបានទៀងទាត់ដើម្បីកាត់បន្ថយការបង្កភាពកខ្វក់ដល់កសិផល ។

៤៩ ត្រូវរក្សាទុកឧបករណ៍ ប្រអប់/ធុង និងសម្ភារៈសំរាប់ផ្ទុកកសិផល នៅកន្លែងដាច់ដោយឡែកពីសារធាតុគីមី ជី ឬសារធាតុកែលម្អបង្កើនជីជាតិដី និងត្រូវចាត់វិធានការកាត់បន្ថយភាពកខ្វក់ដល់កសិផលដែលបង្កឡើងដោយសមាសភាពផ្សេង ។

៥០ ត្រូវពិនិត្យមើលភាពរឹងមាំ និងភាពស្អាតរបស់ឧបករណ៍ ធុង/ប្រអប់ និងសម្ភារៈសម្រាប់ផ្ទុកកសិផល នៅរាល់មុនពេលប្រើ និងត្រូវសំអាត ជួសជុល ឬក៏បោះចោល ប្រសិនបើចាំបាច់ ។

៥១ មិនត្រូវដាក់កសិផលដែលបានប្រមូលផលរួចនៅផ្ទាល់នឹងដី ឬ ផ្ទាល់នឹងកំរាលនៃកន្លែងលើកដាក់ប្រើប្រាស់ វេចខ្ចប់ ឬរក្សាទុកកសិផលឡើយ ។

### ច.២. អាគារ និងសំណង់

៥២ ត្រូវតែសាងសង់ និងថែរទាំអាគារ និងបណ្តាសំណង់ដែលប្រើសំរាប់ដាំដុះ វេចខ្ចប់ លើកដាក់ និងរក្សាទុកកសិផល ដើម្បីកាត់បន្ថយហានិភ័យដែលធ្វើឱ្យមានភាពកខ្វក់ដល់កសិផល ។

៥៣ ត្រូវទុកដាក់ ខ្លាញ់ ប្រេង ប្រេងឥន្ធនៈ និងគ្រឿងម៉ាស៊ីនសំរាប់ប្រើនៅចំការ ឱ្យនៅដោយឡែកពីកន្លែងលើកដាក់ប្រើប្រាស់ វេចខ្ចប់ និងរក្សាទុកកសិផល ដើម្បីទប់ស្កាត់ការធ្វើឱ្យកខ្វក់ដល់កសិផល ។

៥៤ ត្រូវសាងសង់ប្រព័ន្ធទឹកស្អុយ ប្រព័ន្ធបញ្ចេញកាកសំណល់ និងប្រព័ន្ធបង្ហូរទឹក ក្នុងបំណងដើម្បីកាត់បន្ថយហានិភ័យនៃការបង្កភាពកខ្វក់ដល់កន្លែងផលិតកម្ម និងការផ្គត់ផ្គង់ទឹក ។

៥៥ ត្រូវមានប្រដាប់ការពារអំពូលភ្លើងដែលនៅពីលើកន្លែងដែលរក្សាទុក ប្រអប់/ធុង និង សម្ភារៈដាក់កសិផល និងបណ្តាសម្ភារៈសម្រាប់វេចខ្ចប់កសិផលដើម្បីបង្ការការពារអម្បែងបែកដែលអាចនឹងធ្លាក់ចូលកសិផល នៅក្នុងករណីដែលមានការបែកអំពូលភ្លើង។ ត្រូវតែបោះចោលនូវកសិផលដែលមានធ្លាក់អម្បែងអំពូលចូល ហើយត្រូវសំអាតឧបករណ៍ និងប្រអប់/ធុង និងសម្ភារៈវេចខ្ចប់កសិផល ឱ្យបានស្អាតឡើងវិញ ។

៥៦ ត្រូវប្រើនាំងបាំង ផ្តាច់ដោយឡែក រវាងឧបករណ៍ និងប្រដាប់ប្រដាដែលអាចជាប្រភពបង្កគ្រោះថ្នាក់រូបសាស្ត្រ ដល់មនុស្ស ដែលស្ថិតនៅក្នុងអាគារជាមួយនឹងកន្លែងលើកដាក់ ប្រើប្រាស់ វេចខ្ចប់ និងរក្សាទុកកសិផល និងមិនត្រូវប្រើវានៅក្នុងពេលកំពុងវេចខ្ចប់ លើកដាក់ ប្រើប្រាស់ និងរក្សាទុកកសិផលឡើយ ។

### ច.៣. ការសំអាត និងការធ្វើអនាម័យ

៥៧ ត្រូវធ្វើអត្តសញ្ញាណរាល់ទីកន្លែង ឧបករណ៍ ប្រដាប់ប្រដា ធុង/ប្រអប់ និងសម្ភារៈវេចខ្ចប់ លើកដាក់ ប្រើប្រាស់ ដែលអាចជាប្រភពនៃការបង្កភាពកខ្វក់ដល់កសិផល និងត្រូវរៀបចំឱ្យមានរបៀបរៀបរយល្អ និងត្រូវសំអាតធ្វើអនាម័យជា

Created with nitro PDF professional
download the free trial online at nitropdf.com/professional

ប្រចាំ។

៥៨ ត្រូវជ្រើសរើសសារធាតុគីមីសមស្រប សម្រាប់ប្រើក្នុងការសំអាត និងធ្វើអនាម័យ ដើម្បីកាត់បន្ថយហានិភ័យដែលបង្កឱ្យមានភាពកខ្វក់ដល់កសិផលដោយសារធាតុគីមី ។

## ច.៤. ការកំចាត់សត្វ និងសមាសភាពចង្រៃ

៥៩ មិនត្រូវឱ្យសត្វបក្សី និងសត្វពាហនៈ ឬសត្វចង្រៃដទៃទៀត ចូលទៅក្នុងកន្លែងផលិតកម្ម (ជាពិសេសចំពោះដំណាំដែលដាំដោយផ្ទាល់ ឬ ជិតនឹងដី) កន្លែងប្រមូលផល វេចខ្ចប់ និងទុកដាក់កសិផលឡើយ ។

៦០ ត្រូវចាត់វិធានការបង្ការ និងទប់ស្កាត់នូវវត្តមានរបស់សមាភាពចង្រៃ ទោះបីជានៅក្នុង និងជុំវិញកន្លែងលើកដាក់ វេចខ្ចប់ និងទុកដាក់កសិផល ។

៦១ ត្រូវតែកំណត់ទីតាំង និងថែទាំ ឬ គ្រប់គ្រងនុយបំពុល និងអន្ទាក់ដែលប្រើសម្រាប់កំចាត់សមាសភាពចង្រៃ ដើម្បីកាត់បន្ថយហានិភ័យដែលបង្កឱ្យមានភាពកខ្វក់ដល់កសិផល ធុង/ប្រអប់ និងសម្ភារៈវេចខ្ចប់កសិផល ។ ទីតាំងដាក់នុយបំពុល និងអន្ទាក់ ត្រូវតែកត់ត្រាទុកឱ្យបានច្បាស់លាស់ ។

## ច.៥. អនាម័យផ្ទាល់ខ្លួន

៦២ ត្រូវអនុញ្ញាតឱ្យធ្វើការតែកម្មករដែលមានចំណេះដឹងសមរម្យ ឬ ត្រូវបណ្តុះបណ្តាលពួកគេអំពីការអនុវត្តអនាម័យផ្ទាល់ខ្លួន ហើយឯកសារអំពីការបណ្តុះបណ្តាលទាំងនោះត្រូវតែរក្សាទុក ។

៦៣ ត្រូវចែក ឬបិទផ្សាយនៅកន្លែងដែលងាយមើលឃើញ នូវសេចក្តីណែនាំជាលាយល័ក្ខអក្សរអំពីការអនុវត្តអនាម័យផ្ទាល់ខ្លួនដល់កម្មករ ។

៦៤ ត្រូវរៀបចំឱ្យមានបង្គន់ និងកន្លែងលាងសំអាតដៃឱ្យបានត្រឹមត្រូវសំរាប់កម្មករ និងត្រូវថែទាំឱ្យមានអនាម័យជាប្រចាំ ។

៦៥ ត្រូវតែមានប្រព័ន្ធបង្ហូរទឹកស្អុយចោល តាមវិធីដែលអាចកាត់បន្ថយហានិភ័យដែលអាចបង្កភាពកខ្វក់ដោយផ្ទាល់ ឬដោយប្រយោលដល់កសិផល ។

## ច.៦. ការធ្វើប្រព្រឹត្តិកម្មកសិផល

៦៦ ត្រូវអនុវត្តដូចគ្នាទៅនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកសារធាតុគីមី ចំពោះការប្រើប្រាស់ រក្សាទុក និងការកម្ទេចចោលសារធាតុគីមីដែលបានប្រើក្នុងពេលបន្ទាប់ពីការប្រមូលផល រួមមាន ថ្នាំកសិកម្ម និងសារធាតុរលាយផ្សេងទៀត ។

៦៧ ត្រូវអនុវត្តដូចគ្នាទៅនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកទឹក ចំពោះការប្រើប្រាស់ទឹកសម្រាប់ធ្វើប្រព្រឹត្តកម្មកសិផលក្រោយពេលប្រមូលផល ។

៦៨ ត្រូវប្រើទឹកដែលមានគុណភាពស្មើនឹងស្តង់ដារទឹកសំរាប់ផឹក ក្នុងការសំអាតចុងក្រោយសម្រាប់លាងផ្នែកដែលបរិភោគបានរបស់កសិផល ។

## ច.៧. ការរក្សាទុក និងការដឹងជញ្ជូន

៦៩ មិនត្រូវដាក់ប្រអប់/ធុង/ថប និងសម្ភារៈវេចខ្ចប់ដែលមានផ្ទុកកសិផលផ្ទាល់នៅលើដី ជាពិសេសនៅកន្លែងដែលមានហានិភ័យខ្ពស់ដែលអាចធ្វើឱ្យកខ្វក់ដល់កសិផលដោយសារដីដែលជាប់នឹងបាតប្រ

Created with nitroPDF professional
download the free trial online at nitropdf.com/professional

នោះ។

៧០ ត្រូវពិនិត្យមើលកំណល់ឈើ (ប៉ាឡែត) សម្រាប់ទ្រាប់ជាទម្រកសិផលបានឱ្យស្អាត កុំឱ្យមានប្រឡាក់សារធាតុគីមី កំទេចកំទី និងការរាតត្បាតដោយសមាសភាពចង្រៃ។ មុននឹងប្រើទ្រនាប់ទាំងនោះ ត្រូវតែធ្វើការសំអាតរួចគ្របទ្រាប់ដោយប្រើគំរបការពារ ឬត្រូវបោះវាចោលប្រសិនបើពិនិត្យឃើញថា មានហានិភ័យខ្ពស់ដែលអាចធ្វើឱ្យកខ្វក់ដល់កសិផល។

៧១ ត្រូវសំអាតយានយន្តសម្រាប់ដឹកជញ្ជូនកុំឱ្យមានប្រឡាក់សារធាតុគីមី មិនមានកម្ទេចកម្ទីផ្សេងៗ និងមិនមានការរុករានរបស់សមាសភាពចង្រៃ។ នៅមុនពេលនៃការប្រើប្រាស់ត្រូវសំអាតជាចាំបាច់ និងចៀសវាងការប្រើប្រាស់ប្រសិនបើពិនិត្យឃើញថា មានហានិភ័យខ្ពស់ដែលអាចធ្វើឱ្យមានភាពកខ្វក់ដល់កសិផល។

៧២ ត្រូវតែរក្សាទុក និងដឹកជញ្ជូនកសិផលដាច់ដោយឡែកពីទំនិញដែលជាប្រភពនៃភាពកខ្វក់គីមី ជីវសាស្ត្រ និងរូបសាស្ត្រ។

## ច.៨. កំណត់ចំណាំដើម្បីងាយរក និងប្រមូលត្រឡប់មកវិញ

៧៣ ត្រូវកំណត់អត្តសញ្ញាណផ្សេងគ្នា ដោយឈ្មោះ ឬលេខកូដ ចំពោះរាល់ទីកន្លែងផលិតកម្មដាច់ដោយឡែកពីគ្នានីមួយៗ។ ឈ្មោះ ឬលេខកូដទាំងនោះ ត្រូវមានដាក់ជាស្លាកនៅតាមទីកន្លែង និងត្រូវកត់ត្រានៅលើផែនទីចំការ។ ឈ្មោះ ឬលេខកូដទីកន្លែង ត្រូវកត់ត្រានៅលើឯកសារ និងកំណត់ត្រាទាំងអស់ដែលពាក់ព័ន្ធទៅនឹងទីកន្លែងនោះ។

៧៤ ត្រូវតែដាក់អត្តសញ្ញាណសំគាល់ឱ្យច្បាស់លាស់នៅលើប្រអប់/ធុង កសិផលដែលបានវេចខ្ចប់ ដើម្បីងាយស្រាវជ្រាវរកឃើញចំការ ឬ ទីកន្លែងដែលបានដាំ។

៧៥ ត្រូវរក្សាទុកកំណត់ត្រាអំពីកាលបរិច្ឆេទនៃការបែងចែកផ្គត់ផ្គង់ និងទិសដៅកសិផលមួយមុខៗ។

៧៦ ត្រូវតែទុកដាក់កសិផលដែលបានកំណត់អត្តសញ្ញាណឃើញថា បានទទួលរងនូវភាពកខ្វក់ ឬមានសក្តានុពលកខ្វក់ឱ្យនៅឆ្ងាយដាច់ដោយឡែកពីគេ និងត្រូវទប់ស្កាត់ការចែកចាយ ឬប្រសិនបើកសិផលនោះ បានលក់ចេញទៅហើយនោះ ត្រូវតែជូនដំណឹងជាបន្ទាន់ដល់អ្នកទិញ។

៧៧ ត្រូវស៊ើបអង្កេតនូវមូលហេតុដែលបង្កឱ្យមានភាពកខ្វក់ទាំងឡាយ និងត្រូវចាត់វិធានការទប់ស្កាត់កុំឱ្យកើតមានឡើងម្តងទៀត និងត្រូវកត់ត្រាទុកនូវហេតុការណ៍នោះ និងវិធានការនានាដែលបានប្រើ។

## ឆ. ការបណ្តុះបណ្តាល

៧៨ និយោជក និងកម្មករត្រូវមានចំណេះដឹងសមរម្យ ឬត្រូវបណ្តុះបណ្តាលនៅក្នុងដែនទទួលខុសត្រូវទាក់ទិននឹងវិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ដោយអគ្គនាយកដ្ឋានកសិកម្ម។ រាល់ឯកសារអំពីការបណ្តុះបណ្តាលត្រូវតែរក្សាទុក។

## ជ. ឯកសារ និងកំណត់ត្រានានា

៧៩ ត្រូវតែរក្សាទុកកំណត់ត្រាអំពីវិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ក្នុងរយៈពេលយ៉ាងតិចពីរឆ្នាំ ឬ ក្នុងរយៈពេលវែងជាងនេះតាមការតម្រូវរបស់រដ្ឋាភិបាល ឬ អតិថិជន។

Created with nitro PDF professional
download the free trial online at nitropdf.com/professional

៨០ ឯកសារចាស់ហួសសម័យត្រូវតែបោះចោល និងត្រូវប្រើតែច្បាប់កំណែថ្មីប៉ុណ្ណោះ ។

### ឈ. ការពិនិត្យមើលឡើងវិញនូវការអនុវត្ត

៨១ ត្រូវតែធ្វើការពិនិត្យមើលឡើងវិញនូវរាល់ការអនុវត្តទាំងឡាយ យ៉ាងហោចណាស់មួយឆ្នាំម្តងដើម្បីធានាថា ការអនុវត្តទាំងនោះបានធ្វើឡើងត្រឹមត្រូវ និងត្រូវចាត់វិធានការកែតម្រូវចំពោះកំហុសឆ្គងណាមួយដែលបានរកឃើញ។ ត្រូវរក្សាទុកកំណត់ត្រាអំពីការអនុវត្តដែលបានពិនិត្យមើលឡើងវិញ និងវិធានការកែលំអនានា ។

៨២ ត្រូវចាត់វិធានការដើម្បីដោះស្រាយការតវ៉ាទាំងឡាយ ទាក់ទងទៅនឹងសុវត្ថិភាពចំណីអាហារ និងត្រូវកត់ត្រាទុកនូវរាល់ការតវ៉ា និងវិធានការដែលប្រើ ។

## II. PRODUCT QUALITY

## ២. ផ្នែកគុណភាពកសិផល

### ក. ផែនការគុណភាព

៨៣ ត្រូវកំណត់ការអនុវត្តក្នុងផែនការដាំដុះដំណាំឱ្យបានច្បាស់លាស់ដើម្បីគ្រប់គ្រងគុណភាពកសិផលនៅក្នុងពេលផលិតកម្ម ពេលប្រមូលផល និងការថែរក្សាក្រោយពេលប្រមូលផល ។

### ខ. ពូជ និងបំណែកពូជដំណាំ

៨៤ ត្រូវជ្រើសរើសពូជដំណាំទៅតាមតម្រូវការរបស់ទីផ្សារ ។

៨៥ ត្រូវមានវិញ្ញាបនបត្រសុខភាពដំណាំប្រសិនបើពូជដំណាំនោះ ទទួលបានមកពីចំការ ឬ កន្លែងបណ្តុះផ្សេង ដើម្បីឱ្យប្រាកដថា ពូជដំណាំដែលផ្តល់ឱ្យដោយអ្នកផ្គត់ផ្គង់ពិតជាមានគុណភាពល្អ ។

### គ. ជី និងសារធាតុកែលម្អបង្កើនជីជាតិដី

៨៦ ត្រូវប្រើប្រាស់ជីស្របទៅតាមអនុសាសន៍របស់អាជ្ញាធរមានសមត្ថកិច្ច (អគ្គនាយកដ្ឋានកសិកម្ម) ឬអាស្រ័យទៅតាមលទ្ធផលជាក់ស្តែងនៃការវិភាគដី ឬ វិភាគស្លឹករុក្ខជាតិ ឬ វិភាគរុក្ខរស និងតំរូវការជីជាតិសម្រាប់ដំណាំដែលដាំ ។

៨៧ ត្រូវថែទាំឧបករណ៍ដែលប្រើសម្រាប់ដាក់ជី និងសារធាតុកែលម្អបង្កើនជីជាតិដីឱ្យបានល្អ ដោយពិនិត្យមើលប្រសិទ្ធភាពការងាររបស់វាយ៉ាងហោចណាស់មួយឆ្នាំម្តងដោយអ្នកដែលមានសមត្ថភាពបច្ចេកទេស ។

៨៨ ត្រូវជ្រើសទីតាំង និងសាងសង់កន្លែងសម្រាប់ធ្វើកំប៉ុស្តសារធាតុសរីរាង្គឱ្យបានល្អ ដើម្បីបង្ការការចម្លងរោគលើដំណាំ ។

៨៩ ត្រូវកត់ត្រាទុកនូវការប្រើជី និងសារធាតុកែលម្អបង្កើនជីជាតិដី ដោយបរិយាយពិស្តារអំពីឈ្មោះផលិតផល ឬសារធាតុ កាលបរិច្ឆេទ ទីតាំងធ្វើប្រព្រឹត្តិកម្ម អត្រាប្រើ វិធីសាស្ត្រ និង ឈ្មោះអ្នកប្រើ ។

### ឃ. ទឹក

៩០ ការស្រោចស្រព ត្រូវអនុវត្តដោយផ្អែកទៅលើតម្រូវការទឹករបស់ដំណាំ ទឹកដែល

Created with nitroPDF professional
download the free trial online at nitropdf.com/professional

៩១ ត្រូវធ្វើកំណត់ត្រានៃការស្រោចស្រព ដោយពណ៌នាលម្អិតអំពីដំណាំ កាលបរិច្ឆេទ ទីតាំង ចំណុះទឹកដែលបានប្រើ ឬ រយៈពេលនៃការស្រោចស្រព។

## ង. សារធាតុគីមី

### ង.១. គ្រឿងគីមី

៩២ ត្រូវបណ្តុះបណ្តាលនិយោជក និងកម្មករ ក្នុងកិរិតមួយសមរម្យទៅនឹងភារៈកិច្ច និងការទទួលខុសត្រូវលើការប្រើប្រាស់សារធាតុគីមី។

៩៣ ត្រូវចាត់វិធានការសមស្របក្នុងកិច្ចការពារដំណាំសម្រាប់ការកម្ចាត់សមាសភាពចង្រៃ។

៩៤ ត្រូវប្រើប្រព័ន្ធវិធានការចម្រុះគ្រប់គ្រងដំណាំ ( IPM ) ទៅតាមលទ្ធភាពដែលអាចធ្វើបាន។

៩៥ ត្រូវទិញសារធាតុគីមីពីអ្នកលក់ដែលមានលិខិតអនុញ្ញាតធ្វើអាជីវកម្មស្របច្បាប់។

៩៦ ត្រូវប្រើប្រភេទសារធាតុគីមីលើមុខដំណាំដែលបានទទួលការឯកភាពពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសផលិត និង ប្រទេសនាំចូល ហើយត្រូវមានតម្កល់ឯកសារដើម្បីបញ្ជាក់ពីការឯកភាពទាំងនោះ។

៩៧ ត្រូវប្រើប្រាស់សារធាតុគីមីទៅតាមសេចក្តីណែនាំនៅលើស្លាកសញ្ញា ឬ តាមគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានកសិកម្ម ឬ អាជ្ញាធរមានសមត្ថកិច្ច។

៩៨ ត្រូវប្រើយុទ្ធសាស្ត្រនៃការប្រើសារធាតុគីមីឆ្លាស់ និងវិធានការការពារដំណាំដទៃទៀត ដើម្បីចៀសវាងនូវភាពធន់របស់សមាសភាពចង្រៃ។

៩៩ ត្រូវថែទាំឧបករណ៍ដែលប្រើសម្រាប់ប្រើសារធាតុគីមីឱ្យបានល្អ និងពិនិត្យមើលប្រសិទ្ធភាពការងារឱ្យបានទៀងទាត់យ៉ាងហោចណាស់មួយឆ្នាំម្តង ដោយអ្នកដែលមានសមត្ថភាពបច្ចេកទេស។

១០០ ត្រូវកត់ត្រាទុកនូវការប្រើប្រាស់សារធាតុគីមីលើដំណាំមួយមុខៗ ដោយបញ្ជាក់យ៉ាងពិស្តារអំពីសារធាតុគីមីដែលបានប្រើ មូលហេតុនៃការប្រើ កាលបរិច្ឆេទប្រើ ទីតាំងធ្វើប្រព្រឹត្តកម្ម អត្រា និងវិធីសាស្ត្រប្រើ លក្ខខណ្ឌអាកាសធាតុ និងឈ្មោះអ្នកប្រើ។

## ច. ការប្រមូលផល និងការថែរក្សាទុកដាក់កសិផល

### ច.១. ការប្រមូលផល

១០១ ត្រូវប្រើសន្ទស្សន៍នៃភាពចំណាស់ (ស្ថានភាពត្រូវប្រមូលផល) សមស្រប ដើម្បីកំណត់ពេលប្រមូលផល។

១០២ ត្រូវប្រើបច្ចេកទេសសមស្របក្នុងការប្រមូលផលកសិផល។

១០៣ ត្រូវធានាថា ឧបករណ៍ និងបរិក្ខារសម្រាប់ប្រមូលផល គឺមានលក្ខណៈសមស្រប ហើយឧបករណ៍ទាំងនោះ ត្រូវតែស្អាតមុននឹងប្រើ ឬត្រូវសម្អាតតាមការចាំបាច់។

១០៤ ត្រូវប្រើ កេះ/ធុងដែលសមស្របសម្រាប់ការប្រមូលផលកសិផល និងមិនត្រូវដាក់ឱ្យហួសចំណុះឡើយ។

១០៥ ត្រូវប្រើទ្រនាប់ដើម្បីការពារកសិផល ប្រសិនបើធុង/កេះ សម្រាប់ផ្ទុកមានផ្ទៃគ្រើម។

១០៦ ត្រូវគ្របធុង/កេះ ឱ្យជិតដើម្បីកាត់បន្ថយការបាត់បង់សំណើម និងការពារកុំឱ្យត្រូ

Created with nitroPDF professional
download the free trial online at nitropdf.com/professional

១០៧ ត្រូវពិនិត្យមើលធុង/កេះ ដើម្បីធានាថា មាំ និងស្អាត មុននឹងប្រើ និងត្រូវសំអាតឱ្យស្អាត ឬក៏ត្រូវបោះចោល ប្រសិនបើមិនល្អ ។

១០៨ ត្រូវប្រមូលផលកសិផលនៅពេលអាកាសធាតុត្រជាក់ និងត្រូវចៀសវាងការប្រមូលផលនៅពេលភ្លៀង ប្រសិនបើអាចធ្វើបាន ។

១០៩ ត្រូវដឹកជញ្ជូនកសិផលចេញពីទីវាល (ចំការ) ឱ្យបានលឿនបំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

១១០ ត្រូវដាក់កសិផលដែលប្រមូលផលរួចនៅកន្លែងម្លប់ ប្រសិនបើមានការពន្យារពេលយូរក្នុងការដឹកជញ្ជូន ។

១១១ មិនត្រូវដាក់កេះ/ធុងកសិផលត្រួតពីលើគ្នាឡើយ ដើម្បីកាត់បន្ថយការខូចខាតដោយមេកានិក លុះត្រាតែកេះ/ធុងទាំងនោះ បានរចនាឡើងរឹងមាំ និងអាចកាត់បន្ថយការខូចខាតដោយមេកានិក ។

១១២ ត្រូវដាក់កេះ/ធុងកសិផលឱ្យមានលំនឹងមាំទាំល្អក្នុងពេលដឹកជញ្ជូន ដើម្បីកាត់បន្ថយការខូចខាតដោយមេកានិក ។

## ច.២. ការថែរក្សាទុកដាក់កសិផល

១១៣ ត្រូវរចនាឧបករណ៍ថែរក្សាទុកដាក់កសិផលឱ្យបានល្អ ដើម្បីកាត់បន្ថយការជ្រុះធ្លាក់ និងការប៉ះទង្គិចខ្លាំង ។

១១៤ ត្រូវសំអាត និងថែទាំជាប្រចាំនូវឧបករណ៍ កេះ/ធុង និងសម្ភារៈដែលប្រើប្រាស់សម្រាប់ទុកដាក់កសិផល ដើម្បីកាត់បន្ថយការខូចខាតដោយមេកានិក ។

១១៥ ត្រូវចាត់វិធានការដើម្បីកាត់បន្ថយវត្តមានសមាសភាពចង្រៃនៅក្នុង និងនៅជុំវិញកន្លែងថែរក្សាទុកដាក់ វេចខ្ចប់ ឬកន្លែងរក្សាទុកកសិផល ។

១១៦ ត្រូវធ្វើប្រព្រឹត្តិកម្មដើម្បីកាត់បន្ថយការវិវត្តន៍របស់ជម្ងឺ និងការបាត់បង់គុណភាពកសិផលក្នុងករណីដែលមានភាពចាំបាច់ ។

១១៧ ត្រូវធ្វើប្រព្រឹត្តិកម្មទឹកដែលបានប្រើបន្ទាប់ពីការប្រមូលផល ការលាងសំអាត និងធ្វើប្រព្រឹត្តិកម្មកសិផល ឬត្រូវផ្លាស់ប្តូរទឹកជាប្រចាំ ដើម្បីកាត់បន្ថយភាពកខ្វក់ដែលបង្កឡើងដោយសរីរាង្គបង្កការរលួយ ។

១១៨ ត្រូវវេចខ្ចប់កសិផល និងរក្សាទុកនៅក្នុងកន្លែងបិទបាំង (ដែលមានដំបូល) ។

១១៩ មិនត្រូវដាក់កសិផលដោយផ្ទាល់នៅលើដី ឬ លើកំរាលនៃកន្លែងសម្រាប់ការចាត់ថែង វេចខ្ចប់ ឬរក្សាទុកឡើយ ។

១២០ ត្រូវចាត់ថ្នាក់កសិផល និងធ្វើការវេចខ្ចប់ទៅតាមតម្រូវការរបស់អតិថិជន ឬទីផ្សារ ។

១២១ ត្រូវប្រើទ្រនាប់សម្រាប់ការពារទៅតាមភាពចាំបាច់ ដើម្បីការពារកសិផលពីការប៉ះផ្ទៃគ្រើមរបស់ធុង/កេះ និងពីការបាត់បង់សំណើមខ្លាំង ។

១២២ ត្រូវបញ្ចុះកំដៅកសិផលដែលទើបយកមកពីចំការដោយប្រើវិធីសាស្ត្រធ្វើឱ្យត្រជាក់សមរម្យតាមលក្ខណៈបច្ចេកទេស ។

## ច.៣. ការរក្សាទុក និងការដឹកជញ្ជូន

១២៣ ត្រូវរក្សាទុកកសិផលនៅកន្លែងដែលមានសីតុណ្ហភាពទាបតាមតែអាចធ្វើបាន ក្នុងករណីដែលមានការពន្យារពេលយូរមុនពេលដឹកជញ្ជូន ។

១២៤ ត្រូវគ្របបិទបាំងយានយន្តដែលដឹកជញ្ជូនកសិផល និងត្រូវប្រើលក្ខខណ្ឌសីតុណ្ហភាពសមស្រប ដើម្បីកាត់បន្ថយការបាត់បង់គុណភាព ។

១២៥ ត្រូវពិនិត្យមើលភាពស្អាត វត្តមានកម្ទេចកម្ទី និងភាពរំខានរបស់សត្វចង្រៃ

Created with nitroPDF professional
download the free trial online at nitropdf.com/professional

ត្រូវធ្វើការសំអាត ប្រសិនបើសង្កេតឃើញមានហានិភ័យខ្ពស់ក្នុងការបង្កការខូចខាតតាមលក្ខណៈមេកានិក និងភាពកខ្វក់ដែលបង្កឡើងដោយសរីរាង្គបង្កការរលួយ ។

១២៦ ត្រូវចៀសវាងការដាក់លាយចម្រុះកសិផលដែលមិនត្រូវធាតុគ្នា (បង្កឱ្យខូច) ក្នុងពេលដឹកជញ្ជូន ។

១២៧ ត្រូវដឹកជញ្ជូនកសិផលទៅកាន់គោលដៅភ្លាមៗ ។

## ឆ. កំណត់ចំណាំដើម្បីងាយរក និងប្រមូលត្រឡប់មកវិញ

១២៨ ទីកន្លែងនៃផលិតកម្មដាច់ដោយឡែកនីមួយៗអាចកំណត់អត្តសញ្ញាណបានដោយឈ្មោះ ឬ លេខកូដ។ សញ្ញាសម្គាល់ភ្ជាប់ជាមួយឈ្មោះ ឬ លេខកូដត្រូវដាក់បង្ហាញនៅតាមទីកន្លែងផលិត និងត្រូវកត់ត្រានៅលើផែនទីចំការ។ ឈ្មោះទីតាំង ឬលេខកូដ ត្រូវកត់ត្រានៅលើឯកសារ និងកំណត់ត្រាដែលមានទំនាក់ទំនងទៅនឹងទីកន្លែងនោះ។

១២៩ ត្រូវដាក់អត្តសញ្ញាណសម្គាល់ឱ្យច្បាស់លាស់លើកេះ/ធុងកសិផលដែលបានវេចខ្ចប់ ដើម្បីងាយស្វែងរកឃើញចំការ ឬទីកន្លែងដែលបានដាំ។

១៣០ ត្រូវរក្សាទុកកំណត់ត្រាអំពីកាលបរិច្ឆេទនៃការផ្គត់ផ្គង់ និងទិសដៅទំនិញកសិផលនីមួយៗដែលត្រូវដឹកជញ្ជូន ។

## ជ. ការបណ្តុះបណ្តាល

១៣១ និយោជក និងកម្មករត្រូវមានចំណេះដឹងសមរម្យ ឬត្រូវបណ្តុះបណ្តាលនៅក្នុងដែនទទួលខុសត្រូវពាក់ព័ន្ធនឹងវិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់។ រាល់ឯកសារអំពីការបណ្តុះបណ្តាលត្រូវតែរក្សាទុក។

## ឈ. ឯកសារ និងកំណត់ត្រា

១៣២ ត្រូវរក្សាកំណត់ត្រាអំពីការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មរយៈពេលពីរឆ្នាំយ៉ាងតិច ឬវែងជាងនេះ ប្រសិនបើមានតម្រូវការពីរដ្ឋាភិបាល ឬអតិថិជន។

១៣៣ ត្រូវប្រើឯកសារថ្មី និងត្រូវបោះចោលនូវឯកសារដែលផុតកំណត់ប្រើប្រាស់។

## ញ. ការពិនិត្យមើលឡើងវិញលើការអនុវត្ត

១៣៤ ត្រូវតែពិនិត្យមើលឡើងវិញលើរាល់ការអនុវត្តកន្លងមកទាំងអស់យ៉ាងហោចណាស់ក៏ម្តងក្នុងមួយឆ្នាំដែរ ដើម្បីប្រាកដថា ការអនុវត្តទាំងនោះ ពិតជាត្រូវបានធ្វើឡើងត្រឹមត្រូវ និងបានចាត់វិធានការកែតំរូវនូវកំហុសឆ្គងដែលបានរកឃើញ។

១៣៥ ត្រូវរក្សាកំណត់ត្រាទុកដើម្បីបង្ហាញថា រាល់ការអនុវត្តទាំងអស់បានពិនិត្យមើលឡើងវិញ និងត្រូវរក្សាទុកឯកសាររាល់វិធានការកែតំរូវទាំងឡាយ ។

១៣៦ ត្រូវចាត់វិធានការដោះស្រាយការតវ៉ាទាក់ទងទៅនឹងគុណភាពកសិផល និងត្រូវតែធ្វើកំណត់ត្រាទុកអំពីការតវ៉ាទាំងនោះ និងរាល់ការចាត់វិធានការដោះស្រាយនានា ។

Created with nitro PDF professional
download the free trial online at nitropdf.com/professional

# ៣. ផ្នែកសុខភាព, សុវត្ថិភាព និងសុខុមាលភាពកម្មករ

## ក. សារធាតុគីមី

<u>ក្បេរ្យត្រគីមី</u>

១៣៧ ត្រូវថែរក្សាទុកដាក់ និងប្រើប្រាស់សារធាតុគីមីដោយកម្មករដែលមានការអនុញ្ញាតប្រកបដោយចំណេះដឹង និងជំនាញសមស្រប ។

១៣៨ ត្រូវរក្សាសារធាតុគីមីនៅកន្លែងមានខ្យល់ចេញ-ចូលល្អ ក្នុងសំណង់រឹងមាំល្អ និងមានសុវត្ថិភាព ដោយដាក់កំហិតឱ្យចំពោះតែអ្នកដែលមានការអនុញ្ញាតចេញ-ចូលតែប៉ុណ្ណោះ ។ សំណង់ត្រូវកំណត់ទីតាំង និងសាងសង់នៅកន្លែងណាដែលអាចជួយកាត់បន្ថយហានិភ័យដែលធ្វើឱ្យប៉ះពាល់ដល់កម្មករ និងត្រូវបំពាក់ដោយសម្ភារៈសង្គ្រោះបន្ទាន់ ក្នុងករណីមានការកំពប់សារធាតុគីមី ។

១៣៩ ត្រូវរក្សាសារធាតុគីមីនៅក្នុងសំបកវេចខ្ចប់ដើមរបស់វាដែលមានស្លាកសញ្ញាស្របច្បាប់ និងត្រូវរៀបចំទុកដាក់ទៅតាមការណែនាំនៅលើស្លាក ឬដោយអាជ្ញាធរមានសមត្ថកិច្ច (អគ្គនាយកដ្ឋានកសិកម្ម) ។ ប្រសិនបើការមានផ្ទេរសារធាតុគីមីសំបកវេចខ្ចប់ដើមទៅសំបកវេចខ្ចប់ថ្មីមួយទៀតនោះ ត្រូវតែសរសេរចំណាំឱ្យច្បាស់ដោយមានដាក់ឈ្មោះយីហោ កម្រិតប្រើប្រាស់ និងរយៈពេលរង់ចាំក្នុងការប្រើប្រាស់ ។

១៤០ ត្រូវមានសន្លឹកទិន្នន័យសម្ភារៈសុវត្ថិភាព ឬ ការណែនាំអំពីសុវត្ថិភាពដែលបានមកពីស្លាកសញ្ញាសារធាតុគីមីនៅទីកន្លែងណាដែលមានហានិភ័យខ្ពស់ប៉ះពាល់ដល់កម្មករ ។

១៤១ ត្រូវត្រៀមបម្រុងជាស្រេចនូវឧបករណ៍សង្គ្រោះបន្ទាន់សម្រាប់ព្យាបាលដល់កម្មករដែលទទួលការប៉ះពាល់ដោយសារធាតុគីមី ។

១៤២ ត្រូវដាក់តាំងសេចក្តីណែនាំចៀសវាងគ្រោះថ្នាក់ និងការសង្គ្រោះបន្ទាន់នៅទីតាំងដែលងាយមើលឃើញនៅក្នុង ឬ ជិតកន្លែងរក្សាទុកសារធាតុគីមី ។

១៤៣ ត្រូវមានសំលៀកបំពាក់ និងឧបករណ៍ការពារសារធាតុគីមីសមស្របសម្រាប់កម្មករដែលថែរក្សា ទុកដាក់ និងប្រើប្រាស់សារធាតុគីមី និងចូលទៅក្នុងកន្លែងដែលទើបនឹងបាញ់ថ្នាំថ្មីៗ ។

១៤៤ ត្រូវតែសំអាតសំលៀកបំពាក់ការពារ និងរក្សាទុកដាច់ដោយឡែកពីផលិតផលប្រើសម្រាប់ការពារដំណាំ ។

១៤៥ ត្រូវដាក់កំហិតហាមឃាត់ក្នុងកំឡុងពេលសមរម្យចំពោះការចូលទៅកាន់ទីកន្លែងដែលបានប្រើសារធាតុគីមី ឬបានប្រើហើយថ្មីៗទៅតាមប្រភេទសារធាតុគីមីដែលបានប្រើ ។

១៤៦ ត្រូវដាក់សញ្ញាគ្រោះថ្នាក់នៅកន្លែងសាធារណៈដែលមានការប្រើប្រាស់សារធាតុគីមី ។

## ខ. ការប្រមូលផល និងការថែរក្សាទុកដាក់កសិផល

<u>ខ.១. អនាម័យផ្ទាល់ខ្លួន</u>

១៤៧ កម្មករត្រូវមានចំណេះដឹងសមរម្យ ឬត្រូវបានទទួលការបណ្តុះបណ្តាលអំពីការអនុវត្តអនាម័យផ្ទាល់ខ្លួន និងត្រូវរក្សាទុកកំណត់ត្រាអំពីការបណ្តុះបណ្តាលនោះ ។

Created with nitroPDF professional
download the free trial online at nitropdf.com/professional

១៤៨ ត្រូវផ្តល់ដល់កម្មករនូវសេចក្តីណែនាំជាលាយល័ក្ខអក្សរស្តីអំពីការអនុវត្តអនាម័យផ្ទាល់ខ្លួន ឬដាក់តាំងនៅទីតាំងដែលងាយមើលឃើញ ។

១៤៩ ត្រូវតែរៀបចំឱ្យមានជាស្រេចនូវបង្គន់អនាម័យ និងកន្លែងលាងសំអាតដែលសម្រាប់កម្មករ និងត្រូវតែថែទាំឱ្យមានអនាម័យជានិច្ច ។

១៥០ ត្រូវបោះចោលរាល់កាកសំណល់ និងទឹកកខ្វក់តាមរបៀបដើម្បីកាត់បន្ថយហានិភ័យដែលធ្វើឱ្យប៉ះពាល់ដល់កម្មករ ។

១៥១ និយោជកត្រូវផ្តល់ឱ្យកម្មករនូវការចំណាយលើសុខភាព ការព្យាបាលជម្ងឺ និងបើមានបញ្ហាធ្ងន់ធ្ងរណាមួយខាងសុខភាពត្រូវតែរាយការណ៍ទៅកាន់អាជ្ញាធរសុខភាពដែលពាក់ព័ន្ធ ។

១៥២ ត្រូវតែបំពេញនូវការត្រួតពិនិត្យសុខភាពជាចាំបាច់ ចំពោះកម្មករ និងត្រូវរក្សាទុកកំណត់ត្រា ។

១៥៣ ត្រូវចាត់វិធានការដើម្បីកាត់បន្ថយវត្តមានសត្វពាហនៈ និងសត្វចង្រៃដទៃទៀត ដែលជាភ្នាក់ងារចម្លងជម្ងឺនៅក្នុងទីកន្លែងផលិតកម្ម និងជុំវិញកន្លែងថែរក្សាទុកជាក់ វេចខ្ចប់ និងរក្សាទុកកសិផល ។

## ខ.២. លក្ខខណ្ឌការងារ

១៥៤ ត្រូវផ្តល់លក្ខខណ្ឌការងារឱ្យបានសមរម្យសម្រាប់កម្មករ និងត្រូវផ្គត់ផ្គង់សំលៀកបំពាក់ការពារនៅទីណាដែលមានស្ថានភាពគ្រោះថ្នាក់ដល់កម្មករ ។

១៥៥ ត្រូវតែមើលការពារ និងថែទាំរាល់យានយន្ត បរិក្ខារ និងឧបករណ៍ទាំងឡាយ រួមទាំងឧបករណ៍អគ្គិសនី និងមេកានិចឱ្យបានត្រឹមត្រូវ និងពិនិត្យមើលឱ្យបានទៀងទាត់ដើម្បីការពារគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ។

១៥៦ ត្រូវអនុវត្តការលើកដាក់ដោយដៃឱ្យមានសុវត្ថិភាព ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការរងរបួសពីការលើកវត្ថុធ្ងន់ៗជ្រុលហួសពីកម្លាំង ។

## គ. សុខុមាលភាពកម្មករ

១៥៧ ត្រូវរៀបចំផ្តល់ដល់កម្មករនូវកន្លែងរស់នៅ-លំនៅដ្ឋានឱ្យបានសមរម្យ ដោយមានសេវាកម្ម និងសម្ភារៈចាំបាច់នានាក្នុងករណីដែលតម្រូវឱ្យមានការផ្តល់ដោយនិយោជក ។

១៥៨ ត្រូវកំណត់ជ្រើសរើស និងទទួលកម្មករឱ្យចូលបំរើការដែលអាយុស្របតាមគោលការណ៍ច្បាប់ជាធរមាន ។

## ឃ. ការបណ្តុះបណ្តាល

១៥៩ ត្រូវជូនដំណឹងដល់កម្មករថ្មីអំពីហានិភ័យដែលទាក់ទងជាមួយសុខភាព និងវិធានការសុវត្ថិភាពនៅពេលពួកគេចាប់ផ្តើមការងារ ។

១៦០ កម្មករត្រូវមានចំណេះដឹងសមរម្យ ឬ ត្រូវទទួលការបណ្តុះបណ្តាលក្នុងកំរិតសមរម្យទៅនឹងការទទួលខុសត្រូវរបស់ពួកគេទៅតាមចំណេះដឹងដូចខាងក្រោម:

- ការប្រើប្រាស់យានយន្ត ឧបករណ៍ និង បរិក្ខារ
- គ្រោះថ្នាក់ និងវិធីសង្គ្រោះបន្ទាន់
- ការប្រើប្រាស់សារធាតុគីមីដោយសុវត្ថិភាព

Created with nitroPDF professional
download the free trial online at nitropdf.com/professional

- អនាម័យផ្ទាល់ខ្លួន

## ខ. ឯកសារ និងការកត់ត្រា

១៦១ ត្រូវរក្សាទុកកំណត់ត្រាអំពីការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មយ៉ាងហោចណាស់ឱ្យបានរយៈពេលពីរឆ្នាំជាអប្បបរមា ឬ យូរជាងនេះ ប្រសិនបើមានការតម្រូវពីរដ្ឋាភិបាល ឬអតិថិជន។

១៦២ ត្រូវប្រើតែឯកសារថ្មីៗតែប៉ុណ្ណោះ និងត្រូវបោះចោល នូវឯកសារហួសកាលកំណត់ប្រើប្រាស់។

## ច. ការពិនិត្យមើលឡើងវិញនូវការអនុវត្ត

១៦៣ ត្រូវតែពិនិត្យមើលឡើងវិញលើរាល់ការអនុវត្តកន្លងមកទាំងអស់ យ៉ាងហោចណាស់ក៏មួយឆ្នាំម្តងដែរ ដើម្បីប្រាកដថាការអនុវត្តទាំងនោះ ពិតជាត្រូវបានធ្វើឡើងត្រឹមត្រូវ និងត្រូវចាត់វិធានការកែតម្រូវកំហុសឆ្គងដែលបានរកឃើញ។

១៦៤ ត្រូវរក្សាទុកកំណត់ត្រាអំពីការពិនិត្យមើលឡើងវិញ ធ្វើជាភស្តុតាង និងត្រូវទុកជាឯកសារនូវកំហុសឆ្គងដែលបានអនុវត្តកន្លងមក។

១៦៥ ត្រូវចាត់វិធានការដោះស្រាយការតវ៉ាដែលទាក់ទងទៅនឹងសុខភាព សុវត្ថិភាព និងសុខុមាលភាពកម្មករ និងត្រូវតែធ្វើកំណត់ត្រាទុកអំពីការតវ៉ានានា និងរាល់ការចាត់វិធានការទាំងឡាយ ។

# IV.ENVIRONMENT MANAGEMENT

# ៤. ផ្នែកគ្រប់គ្រងបរិស្ថាន

## ក. ប្រវត្តិទីកន្លែង និងការគ្រប់គ្រង

១៦៦ ត្រូវជ្រើសរើសទីកន្លែងសម្រាប់ផលិតកម្មស្របតាមនីតិវិធីដែលបានបញ្ញត្តិកំណត់ទៅតាមរយៈកំពស់ខ្ពស់ និងលើទីជម្រាលខ្លាំង។

១៦៧ ត្រូវធ្វើការវាយតម្លៃអំពីហានិភ័យដែលបង្កឱ្យខូចបរិស្ថាន ចំពោះការប្រើទីកន្លែងផលិតកម្មថ្មី និងត្រូវរក្សាទុកកំណត់ត្រាអំពីសក្តានុពលហានិភ័យទាំងអស់ដែលបានធ្វើអត្តសញ្ញាណ។ ការវាយតំលៃហានិភ័យនេះត្រូវគិតអំពី:

- ប្រវត្តិនៃការប្រើប្រាស់ទីកន្លែងនេះពីមុនមក
- ការជះឥទ្ធិពលជាសក្តានុពលទៅក្នុង និងទៅក្រៅកន្លែងនេះ ដែលអាចបង្កឡើងដោយផលិតកម្មដំណាំ និងការចាត់ចែងក្រោយការប្រមូលផល
- ការជះឥទ្ធិពលពីទីកន្លែងនៅជាប់ជុំវិញចូលមកក្នុងទីផលិតកម្ម។

១៦៨ មិនត្រូវប្រើទីកន្លែងដែលបានកំណត់រកឃើញថា មានហានិភ័យខ្ពស់សម្រាប់ផលិតកម្មដំណាំឡើយ ឬ ក្នុងករណីដែលអាចធ្វើទៅបាននោះ ចាំបាច់ត្រូវចាត់វិធានការដើម្បីបង្ការ ឬ កាត់បន្ថយសក្តានុពលហានិភ័យទាំងនោះជាមុន។

១៦៩ ត្រូវមានប្លង់ផែនទីចំការដែលបង្ហាញអំពីទីតាំងនៃ:

ក. ទីកន្លែងសម្រាប់ផលិតកម្មដំណាំ

ខ. តំបន់ងាយរងការខូចបរិស្ថាន និងតំបន់រិចរិលខ្លាំង

គ. កន្លែងរក្សាទុក និងលាយសារធាតុគីមី កន្លែងសំអាតឧបករណ៍ប្រើជាេ

Created with nitro PDF professional
download the free trial online at nitropdf.com/professional

ក្រោយពេលប្រមូលផល

ឃ. កន្លែង ឬសម្ភារៈសម្រាប់រក្សាទុក សម្រាប់លាយ និងធ្វើជីកំប៉ុស្ត និងសារធាតុកែលម្អ ឬបង្កើនជីជាតិដី

ង. ប្រភពទឹក ទីកន្លែងរក្សាទុក និង ប្រព័ន្ធបង្ហូរច្រោះសំខាន់ៗ កន្លែងបង្ហូរចេញ និងចំណុចបញ្ចេញចោល

ច. អាគារ សំណង់ និងផ្លូវរបស់ចំការ ។

១៧០ ត្រូវគ្រប់គ្រងកន្លែងវិចវិលខ្លាំង ដើម្បីកាត់បន្ថយការវិចវិលបន្ថែមទៀត ។

១៧១ ត្រូវចាត់ការគ្រប់គ្រងសកម្មភាពនានានៅតាមទីកន្លែង ដោយអនុលោមទៅតាមច្បាប់បរិស្ថានរបស់ជាតិដែលមានចែងអំពី ខ្យល់, ទឹក, សំលេង, ដី, ជីវចម្រុះ និងបញ្ហាបរិស្ថានផ្សេងៗទៀត ។

## ខ. ពូជ និង បំណែកពូជដំណាំ

១៧២ ត្រូវជ្រើសរើសប្រើប្រាស់ ពូជ និង បំណែកពូជដំណាំដែលធន់នឹងជម្ងឺ និងសមស្របសម្រាប់ក្បែរបរិស្ថាននៃទីកន្លែងផលិតកម្ម (ដូចជាប្រភេទដី និងកំរិតជីជាតិ) ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមី និងការខ្សោះវិចវិលជីជាតិ ។

## គ. ដី និងមជ្ឈដ្ឋានចិញ្ចឹម

១៧៣ ត្រូវតែគិតគូរឱ្យបានសមស្របទៅនឹងប្រភេទដីនូវរាល់ការអនុវត្តដោយចេតនាលើការងារផលិតកម្ម និងមិនត្រូវបង្កើនហានិភ័យដែលធ្វើឱ្យវិចវិលបរិស្ថានឡើយ ។

១៧៤ ត្រូវរៀបចំផែនទីដី ដើម្បីធ្វើផែនការដាំដំណាំឆ្លាស់ និងកម្មវិធីផលិតកម្មទៅតាមដែលអាចធ្វើទៅបាន ។

១៧៥ ត្រូវអនុវត្តការដាំដុះដែលកែលំអ ឬថែរក្សារចនាសម្ព័ន្ធដី និងកាត់បន្ថយការហាប់ណែន និងការហូរច្រោះរបស់ដី ។

១៧៦ ត្រូវចាត់ការគ្រប់គ្រងឱ្យបានសមស្របចំពោះករណីដែលមានការប្រើប្រាស់ឧស្ម័នពុល ដើម្បីសម្លាប់មេរោគនៅក្នុងដី និងមជ្ឈដ្ឋានចិញ្ចឹម និងត្រូវរក្សាទុកកំណត់ត្រាអំពីទីតាំង កាលបរិច្ឆេទ ផលិតផល អត្រាប្រើប្រាស់ វិធីសាស្ត្រប្រើប្រាស់ និងឈ្មោះអ្នកប្រើប្រាស់ ។

## ឃ. ជី និងសារធាតុកែលម្អបង្កើនជីជាតិដី

១៧៧ ត្រូវចាត់ចែងប្រើជី ដោយផ្អែកលើអនុសាសន៍នៃអាជ្ញាធរមានសមត្ថកិច្ច ឬ ដោយការវិភាគដី វិភាគស្លឹក ឬ វិភាគរុក្ខរស ដើម្បីកាត់បន្ថយការបាត់បង់ និងហូរច្រោះនៃជីជាតិដី ។

១៧៨ ត្រូវកំណត់ទីតាំងក្នុងការសាងសង់ឃ្លាំងស្តុក កន្លែងលាយ-ផ្ទុកជី និងសារធាតុកែលម្អបង្កើនជីជាតិដី និងធ្វើកំប៉ុស្តសារធាតុសរីរាង្គ ដើម្បីកាត់បន្ថយហានិភ័យនៃការប៉ះពាល់បរិស្ថាននៅក្នុង និងខាងក្រៅទីកន្លែងផលិតកម្ម ។

១៧៩ ត្រូវពិនិត្យថែទាំលើប្រសិទ្ធភាពនៃឧបករណ៍ប្រើប្រាស់ក្នុងការដាក់ជី និងសារធាតុកែលម្អបង្កើនជីជាតិដីឱ្យនៅដំណើរការល្អដោយអ្នកដែលមានសមត្ថភាពបច្ចេកទេស យ៉ាងហោចណាស់មួយឆ្នាំម្តង ។

១៨០ ត្រូវតែកត់ត្រាទុកនូវរាល់ការប្រើជី និងសារធាតុកែលម្អបង្កើនជីជាតិដី ដោយបរិយាយពិស្តារអំពីឈ្មោះផលិតផល ឬសារធាតុ កាលបរិច្ឆេទប្រើប្រាស់ ទីតាំងធ្វើប្រព្រឹត្តិកម្ម អត្រាប្រើប្រាស់ វិធីសាស្ត្រប្រើប្រាស់ និងឈ្មោះអ្នកប្រើប្រាស់ ។

១៨១ ត្រូវពិនិត្យតាមដាន កត់ត្រា រាល់ការលាយ ការប្រើប្រាស់ និងការកម្ចេចចោលនូវលាយសារធាតុចិញ្ចឹម កងករណីអនុវត្តប្រព័ន្ធផលិតកម្មលើទឹក (Hydroponics production system) ។

Created with nitro PDF professional
download the free trial online at nitropdf.com/professional

## ខ. ទឹក

១៨២ ត្រូវស្រោចស្រពដោយផ្អែកទៅលើលទ្ធភាពទឹកស្រោចស្រព តម្រូវការទឹករបស់ដំណាំ កម្រិតសើមរបស់ដី និងការពិចារណាអំពីការប៉ះទង្គិចបរិស្ថាននៅក្នុង និងខាងក្រៅទីកន្លែងដាំដុះ ។

១៨៣ ត្រូវប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយការខ្ជះខ្ជាយទឹក និងហានិភ័យនៃការប៉ះពាល់បរិស្ថាននៅក្នុង និងខាងក្រៅកន្លែងដាំដុះ ។

១៨៤ ត្រូវពិនិត្យមើលប្រសិទ្ធភាពការងារនៃប្រព័ន្ធស្រោចស្រពនៅរាល់ពេលប្រើប្រាស់ទៅតាមសេចក្ដីណែនាំរបស់អ្នកផលិត ឬវិធីសាស្ត្រសមស្របដទៃទៀត និងត្រូវថែទាំវាដើម្បីធានានូវប្រសិទ្ធភាពស្រោចស្រព។

១៨៥ ត្រូវរក្សាទុកនូវកំណត់ត្រានៃការស្រោចស្រព ដោយអធិប្បាយលំអិតអំពីដំណាំ កាលបរិច្ឆេទ ទីតាំង ចំណុះទឹកដែលបានប្រើ ឬ រយៈពេលនៃការស្រោចស្រព និងឈ្មោះអ្នកគ្រប់គ្រងសកម្មភាពស្រោចស្រព។

១៨៦ ត្រូវគ្រប់គ្រងលើការប្រមូល ការរក្សាទុក និងការប្រើប្រាស់ទឹក ស្របទៅតាមបញ្ញត្តិច្បាប់ជាតិជាធរមាន។

១៨៧ ត្រូវចាត់ការគ្រប់គ្រង ឬធ្វើប្រព្រឹត្តកម្មទឹក ដែលទទួលបានពីប្រភពផ្សេងៗដែលអាចបង្កការខូចបរិស្ថានដី ផ្លូវទឹក និងតំបន់ងាយរងគ្រោះ ដើម្បីកាត់បន្ថយហានិភ័យនៃការខូចខាតបរិស្ថាន។

១៨៨ ត្រូវបញ្ចេញចោលទឹកកខ្វក់ពីបង្គន់ និងប្រព័ន្ធទឹកសំអុយតាមវិធីដែលអាចកាត់បន្ថយហានិភ័យនៃការខូចបរិស្ថាននៅក្នុង និងខាងក្រៅកន្លែងដាំដុះ។

១៨៩ ត្រូវគ្រប់គ្រង ឬធ្វើប្រព្រឹត្តកម្មទឹកដែលបញ្ចេញមកពីចំការ រួមទាំងទឹកកាកសំណល់ពីការប្រមូលផល និងការលាងសំអាត ដើម្បីកាត់បន្ថយការខូចខាតបរិស្ថាននៅខាងក្រៅទីកន្លែង។

## ច. សារធាតុគីមី

### ច.១. ក្សេត្រគីមី

១៩០ ត្រូវបណ្ដុះបណ្ដាលនិយោជក និងកម្មករនៅក្នុងកម្រិតមួយសមស្របទៅនឹងការងារ និងភាពទទួលខុសត្រូវរបស់ពួកគេក្នុងការប្រើប្រាស់សារធាតុគីមី ។

១៩១ ត្រូវមានភស្តុតាងបញ្ជាក់ពីសមត្ថភាពបច្ចេកទេសរបស់ទីប្រឹក្សាបច្ចេកទេស ដែលមាននាទីជ្រើសរើសផលិតផលគីមីដើម្បីប្រើប្រាស់នៅក្នុងផលិតកម្ម (ក្នុងករណីដែលកន្លែងផលិតកម្មនោះ មានទីប្រឹក្សាបច្ចេកទេសទទួលខុសត្រូវការងារនេះ) ។

១៩២ ត្រូវចាត់ចែងវិធានការសមស្របក្នុងកិច្ចការពារដំណាំដើម្បីកំចាត់សមាសភាពចង្រៃ និងត្រូវផ្អែកទៅលើអនុសាសន៍របស់អគ្គនាយកដ្ឋានកសិកម្ម និងបណ្ដាលិខិតបទដ្ឋានច្បាប់ជាធរមាន។

១៩៣ ត្រូវជំរុញការប្រើប្រាស់ប្រព័ន្ធវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) និងផលិតផលមិនមែនសារធាតុគីមីសំយោគតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមីសំយោគ។

១៩៤ ត្រូវទិញសារធាតុគីមីតែពីអ្នកលក់ដែលបានគោរពតាមនីតិវិធីគ្រប់គ្រងសារធាតុគីមីនៃប្រទេសកម្ពុជា។

១៩៥ ត្រូវប្រើប្រភេទសារធាតុគីមីតាមមុខដំណាំដែលបានកំណត់ដោយអគ្គនាយកដ្ឋានកសិកម្ម និងត្រូវមានតម្កល់ឯកសារដើម្បីបញ្ជាក់ពីការកំណត់នៅមានសុពលភាព។

Created with nitro PDF professional
download the free trial online at nitropdf.com/professional

១៩៦ ត្រូវប្រើប្រាស់សារធាតុគីមីទៅតាមសេចក្តីណែនាំនៅលើស្លាកសញ្ញា ឬតាមគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានកសិកម្ម ។

១៩៧ ត្រូវប្រើយុទ្ធសាស្ត្រនៃការប្រើសារធាតុគីមីឆ្លាស់ និងវិធានការការពារដំណាំដទៃទៀត ដើម្បីចៀសវាងការកើតឡើងនៃភាពធន់របស់សមាសភាពចង្រៃ ។

១៩៨ ត្រូវគ្រប់គ្រងការប្រើសារធាតុគីមី (លើដី និងក្នុងខ្យល់) ដើម្បីកាត់បន្ថយហានិភ័យនៃដំណក់ ឬកំទេចថ្នាំដែលបាញ់ ឬបាចទៅប៉ះចំការ ឬលំនៅស្ថានជិតខាង និងកន្លែងដែលងាយរងការខូចខាតបរិស្ថាន ។

១៩៩ ត្រូវលាយល្បាយសារធាតុគីមីតាមចំណុះសមល្មមនឹងការប្រើ ដើម្បីកាត់បន្ថយចំនួនលើសនៃល្បាយសារធាតុគីមីនៅសល់បន្ទាប់ពីប្រើប្រាស់ ។

២០០ ត្រូវកម្ទេចចោលល្បាយសារធាតុគីមីដែលនៅសល់ និងទឹកលាងសំអាតធុងតាមវិធីដែលអាចជួយកាត់បន្ថយហានិភ័យនៃការខូចខាតបរិស្ថាននៅខាងក្នុង និងក្រៅកន្លែងផលិតកម្ម ។

២០១ ត្រូវថែរក្សាឧបករណ៍ បរិក្ខារដែលប្រើសម្រាប់ដាក់សារធាតុគីមីឱ្យនៅល្អ និងពិនិត្យមើលប្រសិទ្ធភាពការងាររបស់វាយ៉ាងហោចណាស់មួយឆ្នាំម្តងដោយអ្នកដែលមានសមត្ថភាពជំនាញ ។

២០២ ត្រូវរក្សាសារធាតុគីមីនៅកន្លែងសមរម្យ មានខ្យល់អាកាសចេញ-ចូលល្អ និងមានសុវត្ថិភាព ហើយអនុញ្ញាតឱ្យចំពោះតែអ្នកដែលមានសមត្ថកិច្ចចេញ-ចូលតែប៉ុណ្ណោះ ។ ត្រូវកំណត់ទីតាំង និងសាងសង់សំណង់ដើម្បីកាត់បន្ថយហានិភ័យនៃការធ្វើឱ្យកខ្វក់បរិស្ថាន និងត្រូវបំពាក់ដោយសម្ភារៈសង្គ្រោះបន្ទាន់ក្នុងករណីមានការកំពប់សារធាតុគីមី ។

២០៣ ត្រូវរក្សាសារធាតុគីមីនៅក្នុងសម្ភារៈវេចខ្ចប់ដើមរបស់វាដែលមានស្លាកសញ្ញាស្របច្បាប់ និងត្រូវផ្អែកទៅតាមការណែនាំនៅលើស្លាកសញ្ញា ឬពីអគ្គនាយកដ្ឋានកសិកម្ម ។ ប្រសិនបើមានការផ្ទេរសារធាតុគីមីទៅកាន់សម្ភារៈវេចខ្ចប់មួយផ្សេងទៀត សម្ភារៈទុកដាក់ និងវេចខ្ចប់ថ្មីនោះ ត្រូវតែសរសេរចំណាំឱ្យច្បាស់លាស់ដោយមានដាក់ឈ្មោះ យីហោ កម្រិតប្រើ និងរយៈពេលរង់ចាំ ។

២០៤ មិនត្រូវប្រើសម្ភារៈធ្លាប់ទុកដាក់ ឬវេចខ្ចប់សារធាតុគីមីទទេឡើងវិញឡើយ ពោលគឺត្រូវរក្សាទុកវាឱ្យមានសុវត្ថិភាពរហូតដល់ពេលកម្ទេចចោល ។

២០៥ ត្រូវកម្ទេចចោលសម្ភារៈធ្លាប់ទុកដាក់ ឬវេចខ្ចប់សារធាតុគីមីទទេទៅតាមគោលការណ៍ច្បាប់ជាធរមាន និងតាមវិធីសាស្ត្រដែលជួយកាត់បន្ថយហានិភ័យនៃការធ្វើឱ្យប៉ះពាល់ដល់បរិស្ថានខាងក្នុង និងក្រៅទីកន្លែងផលិតកម្ម ។ ត្រូវប្រើប្រព័ន្ធប្រមូល និងកម្ទេចចោលជាផ្លូវការក្នុងករណីដែលមាន ។

២០៦ ត្រូវធ្វើអត្តសញ្ញាណសារធាតុគីមីដែលផុតកំណត់ប្រើប្រាស់ដែលមិនអាចប្រើតទៅទៀតបាន ឬដែលលែងអនុម័តឱ្យប្រើតទៅទៀតឱ្យបានច្បាស់លាស់ និងរក្សាទុកឱ្យបានត្រឹមត្រូវរហូតដល់ពេលកំទេចចោល ។

២០៧ ត្រូវតែកម្ទេចចោលសារធាតុគីមីដែលផុតកំណត់ប្រើប្រាស់តាមរយៈប្រព័ន្ធប្រមូលផ្លូវការ ឬ នៅតាមតំបន់ស្របច្បាប់ណាមួយ ។

២០៨ ត្រូវកត់ត្រាទុកនូវការប្រើប្រាស់សារធាតុគីមីលើដំណាំនីមួយៗដោយបញ្ជាក់យ៉ាងលម្អិតអំពីសារធាតុគីមីដែលបានប្រើ មូលហេតុនៃការប្រើប្រាស់ កាលបរិច្ឆេទប្រើ ទីតាំងធ្វើប្រព្រឹត្តកម្ម កម្រិត
និងឈ្មោះអ្នកប្រើប្រាស់ ។

Created with nitroPDF professional
download the free trial online at nitropdf.com/professional

២០៩ ត្រូវរក្សាទុកកំណត់ត្រានៃសារធាតុគីមីក្នុងស្តុកដោយបញ្ជាក់លម្អិតអំពីឈ្មោះសារធាតុគីមី កាលបរិច្ឆេទ និងបរិមាណដែលបានទិញ និងកាលបរិច្ឆេទនៅពេលដែលប្រើអស់ ឬនៅពេលដែលត្រូវកម្ទេចចោល ។

ច.២.សារធាតុគីមីផ្សេងទៀត

២១០ ត្រូវតែប្រើប្រាស់ រក្សាទុកដាក់ និងកម្ទេចចោលនូវប្រេងឥន្ធនៈ ប្រេង និងសារធាតុដែលមិនមែនជាសារធាតុក្សេត្រគីមីផ្សេងៗទៀត តាមរបៀបដែលជួយដល់ការកាត់បន្ថយហានិភ័យ ឬដែលធ្វើឱ្យកខ្វក់ដល់បរិស្ថាន ។

## ឆ. ការប្រមូលផល និងដំណើរការថែរក្សា ទុកដាក់កសិផល

២១១ ត្រូវអនុវត្តការប្រើប្រាស់ ការរក្សាទុក និងការកម្ទេចចោលសារធាតុគីមីដែលប្រើក្នុងដំណាក់កាលបន្ទាប់ពីការប្រមូលផល ដូចជាថ្នាំកសិកម្ម និងក្រមួន គឺមានគោលការណ៍ដូចគ្នាទៅនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកសារធាតុគីមី ។

## ជ. កាកសំណល់ និងប្រសិទ្ធភាពថាមពល

២១២ ត្រូវចងក្រងជាឯកសារ និងអនុវត្តតាមនូវផែនការគ្រប់គ្រងកាកសំណល់ដោយរាប់បញ្ចូលទាំងការកំណត់អត្តសញ្ញាណប្រភេទកាកសំណល់នៃផលិតផលបន្សល់ពីសកម្មភាពនានារបស់កន្លែងផលិតកម្ម និងរកវិធីសាស្ត្រអនុវត្តដើម្បីកាត់បន្ថយការបង្កើតកាកសំណល់ច្រើន ប្រើប្រាស់កាកសំណល់ឡើងវិញ កែច្នៃប្រើប្រាស់កាកសំណល់ និងដើម្បីរក្សាទុក និងកម្ទេចចោលកាកសំណល់ ។

២១៣ ត្រូវពិនិត្យមើលឡើងវិញនូវប្រសិទ្ធភាពនៃការប្រើប្រាស់អគ្គិសនី និងប្រេងឥន្ធនៈ និងត្រូវកំណត់អត្តសញ្ញាណ និងកែតម្រូវដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព ។

២១៤ ត្រូវថែទាំ និងជួសជុលគ្រឿងម៉ាស៊ីន និងបំពាក់ឧបករណ៍ ដើម្បីរក្សាប្រសិទ្ធភាពការងាររបស់វា ឬត្រូវផ្លាស់ប្តូរចេញ ។

## ឈ. ជីវចម្រុះ

២១៥ ត្រូវគោរពតាមគោលការណ៍ច្បាប់ជាធរមានដែលចែងអំពីរុក្ខជាតិ និងប្រភេទសត្វដែលត្រូវការពារ ដោយចាត់ការគ្រប់គ្រងរាល់សកម្មភាពនៅកន្លែងផលិតកម្មក្នុងទិសដៅធានាថា ប្រភេទដែលត្រូវការពារទាំងនោះ មិនត្រូវបានបំផ្លាញ ។

២១៦ ត្រូវគ្រប់គ្រងអភិរក្សប្រភេទសត្វ និងរុក្ខជាតិក្នុងស្រុក ដោយចំណោត់ការគ្រប់គ្រងសកម្មភាព ក្នុងទិសដៅរក្សាទុកតំបន់សារពើរុក្ខជាតិក្នុងស្រុកសំខាន់ៗដែលនៅសេសសល់ របៀងសត្វព្រៃ និងតំបន់សារពើរុក្ខជាតិនៅ ឬ នៅក្បែរមាត់ទឹក ។

២១៧ ត្រូវចាត់វិធានការដើម្បីកំចាត់សត្វសាហាវ និងសមាសភាពចង្រៃក្នុងបរិស្ថាន ។

## ញ. ខ្យល់

២១៨ ត្រូវតែគ្រប់គ្រងលើការបង្កើតក្លិនមិនល្អ ផ្សែង ធូលី និងសំលេង ដើម្បីកាត់បន្ថយការប៉ះទង្គិចទៅលើតំបន់ជិតខាង ។

Created with nitroPDF professional
download the free trial online at nitropdf.com/professional

## ៨. ការបណ្ដុះបណ្ដាល

២១៩ និយោជក និងកម្មករត្រូវមានចំណេះដឹងសមរម្យ ឬត្រូវបណ្ដុះបណ្ដាលនៅក្នុងផ្នែកដែលទទួលខុសត្រូវរបស់ពួកគេ និងត្រូវឆ្លងវគ្គបណ្ដុះបណ្ដាលអំពីវិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់ ដោយអគ្គនាយកដ្ឋានកសិកម្ម ។ រាល់ឯកសារស្ដីអំពីការបណ្ដុះបណ្ដាលត្រូវតែរក្សាទុក ។

## ៩. ឯកសារ និងកំណត់ត្រា

២២០ ត្រូវរក្សាទុកកំណត់ត្រានៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មក្នុងរយៈពេលយ៉ាងហោចណាស់ពីរឆ្នាំ ឬ វែងជាងនេះ ប្រសិនបើមានការតម្រូវពីនីតិវិធីពាក់ព័ន្ធ និងពីអតិថិជន ។

២២១ ត្រូវបោះបង់ចោលនូវឯកសារចាស់ហួសសម័យ និងប្រើតែឯកសារកំណែថ្មីៗដែលទាក់ទងទៅនឹងការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មតែប៉ុណ្ណោះ ។

## ១០. ការពិនិត្យមើលឡើងវិញនូវការអនុវត្ត

២២២ ត្រូវពិនិត្យមើលឡើងវិញចំពោះការអនុវត្តទាំងអស់ យ៉ាងហោចណាស់មួយឆ្នាំម្ដងដើម្បីប្រាកដថា ការអនុវត្តទាំងនោះ ត្រូវបានធ្វើឡើងត្រឹមត្រូវ និងត្រូវចាត់វិធានការកែតម្រូវកំហុសឆ្គងដែលបានរកឃើញ ឬ កែតម្រូវតាម ប្រសិនបើមានការផ្លាស់ប្ដូរគោលការណ៍ច្បាប់បរិស្ថាន ។

២២៣ ត្រូវរក្សាទុកកំណត់ត្រាអំពីការពិនិត្យមើលឡើងវិញនេះ ដើម្បីជាភស្តុតាង និងត្រូវទុកជាឯកសារនូវរាល់វិធានការកែតម្រូវ ។

២២៤ ត្រូវចាត់វិធានការដោះស្រាយចំពោះការតវ៉ាទាក់ទងទៅនឹងការគ្រប់គ្រងបរិស្ថាន និងត្រូវធ្វើកំណត់ត្រាទុករំពីការតវ៉ានានា និងវិធានការដែលបានប្រើ ។

Created with nitroPDF professional
download the free trial online at nitropdf.com/professional